**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

នៅថ្ងៃអង្គារ ៨រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង ៣:៣០រសៀល គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំអាណត្តិទី១០ លើកទី១ តាមប្រព័ន្ធអនឡាញ (Zoom) ដែលមានសមាសភាពចូលរួម ២៨រូប ដើម្បីពិភាក្សាលើវិធានអនាម័យ និងសុវត្ថិភាពការងារ នៅពេលបើកដំណើរការសកម្មភាព អាជីវកម្មឡើងវិញរបស់រោងចក្រសហគ្រាស ក្រោយបញ្ចប់ការបិទខ្ទប់ដោយវិធានការរដ្ឋបាល។

អង្គប្រជុំទាំងមូលសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាល ដែលជានិច្ចជាកាលតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខុមាលភាពរបស់បងប្អូនកម្មករនិយោជិត តាមរយៈការបន្តផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនដល់បងប្អូនកម្មករនិយោជិត ជាពិសេសកម្មករនិយោជិតដែលរស់នៅក្នុងតំបន់ក្រហម ព្រមទាំងបានផ្តល់ជំនួយឧបត្ថម្ភគ្រឿងឧបភោគបរិភោគចាំបាច់សម្រាប់បងប្អូនកម្មករនិយោជិតនៅតំបន់បិទខ្ទប់។

ក្រោយពីបានពិភាក្សាយ៉ាងយកចិត្តទុកដាក់ និងដើម្បីធានាបាននូវសុខុមាលភាព សុវត្ថិភាព និងជីវភាពរបស់កម្មករនិយោជិត និរន្តរភាពនៃផលិតកម្ម និងភាពអាចព្យាករណ៍បាននៃការផ្គត់ផ្គង់ទំនិញ ក៏ដូចជាចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងរោងចក្រ សហគ្រាស ជាពិសេសរោងចក្រ សហគ្រាសផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប អង្គប្រជុំបានឯកភាពគ្នាជាឯកច្ឆ័ន្ទ ដូចខាងក្រោម៖

## ក. វិធានការរដ្ឋបាលនៅពេលមានករណីវិជ្ជមាននៅតាមរោងចក្រ សហគ្រាស

អង្គប្រជុំតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីកំណត់នូវលក្ខណវិនិច្ឆ័យក្នុងការផ្អាកជាបណ្តោះអាសន្ន និងការបើកដំណើរការឡើងវិញនូវរោងចក្រ សហគ្រាស ដែលមានកម្មករនិយោជិតឆ្លងជំងឺកូវីដ-១៩។

## ខ. កិច្ចព្រមព្រៀងអំពីការបើកដំណើរការសកម្មភាពអាជីវកម្មឡើងវិញរបស់រោងចក្រ សហគ្រាស ក្រោយបញ្ចប់ការបិទខ្ទប់ដោយវិធានការរដ្ឋបាល

នៅពេលបើកដំណើរការសកម្មភាពអាជីវកម្មឡើងវិញ រោងចក្រ សហគ្រាស ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

១. បែងចែកកម្មករនិយោជិតចំនួន ៥០% នៃកម្មករនិយោជិតសរុប ឱ្យធ្វើការឆ្លាស់វេនគ្នារៀងរាល់ ២សប្តាហ៍ម្តង។ ការជ្រើសរើសកម្មករនិយោជិតដែលត្រូវចូលធ្វើការវេនទី១ (២សប្តាហ៍ដំបូង) គឺត្រូវផ្តល់អាទិភាពទៅលើកម្មករនិយោជិតដែល (១) បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី២, (២) បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១, (៣) មិនស្ថិតនៅក្នុងតំបន់ដែលតម្រូវឱ្យផ្តល់សំណាកដើម្បីវិភាគរកមេរោគកូវីដ-១៩ ឬ (៤) បានផ្តល់សំណាកដើម្បីវិភាគរកមេរោគកូវីដ-១៩ (មានចុងលិខិតបញ្ជាក់ដោយក្រុមគ្រូពេទ្យមានសមត្ថកិច្ចយកសំណាក ឬដោយពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ...

២. ផ្តល់ប្រាក់ឈ្នួលចំនួន ៥០% នៃប្រាក់ឈ្នួលអប្បបរមា (ប្រាក់ឈ្នួលអប្បបរមា បូកនឹងប្រាក់អតីតភាពការងារ និងប្រាក់អត្ថប្រយោជន៍ប្រចាំខែផ្សេងៗ ដែលកម្មករនិយោជិតធ្លាប់ទទួលបាននាពេលកន្លងមក) ដោយរក្សាទុកនូវអត្ថប្រយោជន៍ប្រចាំខែ និងអត្ថប្រយោជន៍ផ្សេងៗដូចជា ការថែមម៉ោងចំនួន ២ម៉ោងក្នុង១ថ្ងៃ និងការថែមម៉ោងនៅថ្ងៃអាទិត្យ ។ល។ របស់កម្មករនិយោជិត។

៣. ផ្តល់ម៉ាសយ៉ាងតិចចំនួន ១ ដល់កម្មករនិយោជិតនៅក្នុងអំឡុងម៉ោងការងារ និងត្រូវណែនាំឱ្យកម្មករនិយោជិតពាក់ម៉ាសជាប្រចាំនៅក្នុងកន្លែងការងារ និងពេលប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬរួមគ្នា។

៤. រៀបចំឱ្យមានការបាញ់អាល់កុលលើដៃ និងដងខ្លួន ព្រមទាំងការវាស់កម្តៅមុនពេលចូលធ្វើការ និងក្រោយពេលអាហារថ្ងៃត្រង់។ បន្ថែមឧបករណ៍បាញ់អាល់កុលនៅក្នុងអាគារផលិតកម្ម និងសាប៊ូលាងដៃនៅក្នុងបន្ទប់ទឹក។ បាញ់អាល់កុលម្តងទៀតនៅពេលចេញពីធ្វើការ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ពេលប្រើប្រាស់មធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ឬរួមគ្នា។

៥. បែងចែកវេនសម្រាប់ការបរិភោគអាហារថ្ងៃត្រង់របស់កម្មករនិយោជិតផ្សេងៗគ្នា និងរៀបចំឃាំងរនាំង (ប្រសិនបើអាច) ឬរក្សាបាននូវគម្លាតសុវត្ថិភាពនៅពេលអង្គុយបរិភោគអាហារថ្ងៃត្រង់ ព្រមទាំងលើកទឹកចិត្តឱ្យកម្មករនិយោជិតយកអាហារពីផ្ទះមករៀងៗខ្លួន ជៀសវាងការចេញទៅទិញអាហារនៅខាងក្រៅរោងចក្រ។

៦. រៀបចំឱ្យមានច្រកចេញចូលបន្ថែម ឬបែងចែកពេលវេលា ឬមធ្យោបាយដែលអនុញ្ញាតឱ្យកម្មករនិយោជិតដែលមកបំពេញការងារអាចចេញចូលរោងចក្រ និងទីតាំងផលិតកម្មបានដោយសុវត្ថិភាព និងមិនមានការប្រជ្រៀតគ្នា។

៧. គ្រប់គ្រងប្រព័ន្ធខ្យល់ចេញចូលក្នុងទីតាំងផលិតកម្មឱ្យបានល្អ និងរៀបចំឱ្យមានការបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំសប្តាហ៍។

៨. ជួយសម្របសម្រួលកម្មករនិយោជិត ក្នុងការចរចាជាមួយអ្នកផ្តល់សេវាដឹកជញ្ជូនកម្មករនិយោជិតឱ្យផ្តល់អាល់កុលលាងដៃមុនពេលឡើងយានយន្ត និងលាងសម្អាតយានយន្តនៅពេលដាក់កម្មករនិយោជិតចុះ។

៩. ផ្តល់បញ្ជីឈ្មោះកម្មករនិយោជិត (ដូចមានក្នុងបញ្ជីបើកប្រាក់ឈ្នួលប្រចាំខែមីនា) និងឈ្មោះពេទ្យ ឬគិលានុបដ្ឋាកប្រចាំរោងចក្រ តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមិនគិតថ្លៃសេវា (https://lacms.mlvt.gov.kh/registration/upload/excel) ដើម្បីងាយស្រួលដល់ការធ្វើអន្តរាគមន៍ណាមួយក្នុងករណីចាំបាច់។

១០. រៀបចំឱ្យមានបុគ្គលិកផ្នែករដ្ឋបាលយ៉ាងតិច ២នាក់ ដើម្បីផ្តល់ព័ត៌មានប្រចាំសប្តាហ៍អំពីការអនុវត្តវិធានការរបស់រោងចក្រ និងអំពីករណីសង្ស័យវិជ្ជមានកូវីដ-១៩ ឬអំពីការដាក់ឱ្យកម្មករនិយោជិតណាម្នាក់ធ្វើចត្តាឡីស័កនៅផ្ទះ។

១១. បម្រុងទុកនូវឧបករណ៍យកសំណាកដើម្បីវិភាគរកមេរោគកូវីដ-១៩ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលចំនួន ១០% នៃកម្មករនិយោជិតសរុបរបស់រោងចក្រ ដើម្បីពេទ្យការងារ និងពេទ្យប្រចាំរោងចក្រធ្វើការយកសំណាក ក្នុងករណីចាំបាច់ដូចមាននៅក្នុងចំណុចទី១២ និង១៣។

១២. ត្រូវយកសំណាក ដើម្បីវិភាគរកមេរោគកូវីដ-១៩ រៀងរាល់សប្តាហ៍ចំពោះបុគ្គល ដូចខាងក្រោម៖

- កម្មករនិយោជិតដែលធ្វើការចល័តពីអគារមួយទៅអគារមួយ
- កម្មករនិយោជិតដែលប្រាស្រ័យទាក់ទងជាមួយបុគ្គលខាងក្រៅ ជាពិសេសបុគ្គលដែលមានប្រវត្តិធ្វើដំណើរទៅក្រៅប្រទេស
- កម្មករនិយោជិតដែលធ្វើការនៅអាហារដ្ឋាន
- សន្តិសុខ ឬអ្នកអនាម័យដែលផ្តល់សេវាឆ្លងអគារ
- កម្មករនិយោជិតដែលទទួលបន្ទុកបាញ់សម្លាប់មេរោគ និងវាស់កម្តៅ។

១៣.លើកទឹកចិត្តដល់រោងចក្រ សហគ្រាស ឱ្យយកសំណាកកម្មករនិយោជិតរបស់ខ្លួនដើម្បីវិភាគរកមេរោគ កូវីដ-១៩ រៀងរាល់ខែ ចំនួន ១០% (Random Test)។

១៤.ស្នើសុំរាជរដ្ឋាភិបាលជួយផ្តល់ការឧបត្ថម្ភគ្រឿងឧបភោគបរិភោគជូនបងប្អូនកម្មករនិយោជិតនៅក្នុងអំឡុងពេលផ្អាកសកម្មភាពអាជីវកម្ម ឬពេលកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩ ឬពេលធ្វើចត្តាឡីស័កតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។

លក្ខខណ្ឌនៃការបែងចែងវេនការងាររៀងរាល់ ២សប្តាហ៍ម្តង ត្រូវបានលើកលែងចំពោះរោងចក្រ ដែលមានកម្មករនិយោជិតយ៉ាងតិច ៨០% នៃចំនួនកម្មករនិយោជិតសរុបបានទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ គ្រប់ដូស ឬប្រភេទរោងចក្រ ដែលមានវិធានការសុខភាព និងសុវត្ថិភាពការងារតឹងរឹងក្នុងការការពារកម្មករនិយោជិតពីការកើត ឬឆ្លងជំងឺកូវីដ-១៩ និងទទួលបានការអនុញ្ញាតពីអធិការការងារ។

កម្មករនិយោជិត ដែលស្នាក់នៅក្នុងភូមិសាស្ត្រ ដែលត្រូវបានបិទខ្ទប់ដោយវិធានការរដ្ឋបាលមិនត្រូវបានអនុញ្ញាតឱ្យមកបំពេញការងារនៅក្នុងរោងចក្រ សហគ្រាសដូចបានកំណត់ខាងលើបានឡើយ។

**គ. ការចាក់វ៉ាក់សាំងជូនកម្មករនិយោជិត**

អង្គប្រជុំស្នើសុំរាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពក្នុងការទទួលបានវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដល់៖

- កម្មករនិយោជិតជាពិសេសកម្មករនិយោជិតរោងចក្រ
- អ្នកដឹកជញ្ជូនកម្មករនិយោជិត និងអ្នករត់កង់បី
- អ្នកស្នាក់នៅតំបន់ផ្ទះជួល
- អ្នកលក់ដូរជុំវិញរោងចក្រ
- អាជីវករនៅតាមផ្សារនានា
- បុគ្គលិកបម្រើការនៅតាមភោជនីយដ្ឋាន រមណីយដ្ឋាន និងសណ្ឋាគារ។

គណៈកម្មការប្រឹក្សាការងារ សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមេត្តាពិនិត្យសម្រេចលើកិច្ចព្រមព្រៀងនេះតាមការគួរ។

| តំណាងភាគីនិយោជក | តំណាងភាគីកម្មករនិយោជិត | តំណាងភាគីរាជរដ្ឋាភិបាល |
|---|---|---|
| **ឧកញ៉ាបណ្ឌិត ណាង សុធី** | **លោក សោម អូន** | **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** |